# បងប្អូនប្រុសដែលបញ្ចាំងពន្លឺដល់ពិភពលោក

## ជម្រាបសួរ !

ពួកយើងឈ្មោះ ហូប៊ើត និង ហេឌិន ។

យើងរស់នៅក្នុងប្រទេស ហ្គាណា ។ ទីក្រុងរបស់យើងឈ្មោះអាក្រា គឺវានៅក្បែរមហាសមុទ្រអត្លង់ទិច ។ ប្រទេសយើងក៏មានព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតផងដែរ ។



**១**

**ហេឌិន ៖ ចម្រៀងបុណ្យគ្រីស្ទម៉ាស់**

ថ្នាក់រៀនខ្ញុំនៅសាលាមានការសម្ដែងអំពីប្រសូតកម្ម ហើយខ្ញុំបានលេងព្យាណូសម្រាប់កម្មវិធីទាំងមូល ។ ខ្ញុំបានបង្រៀនមនុស្សគ្រប់គ្នាឲ្យច្រៀងបទ « O Holy Night » ។

**២**

**ហេឌិន ៖ ការបង្រៀនអ្នកជិតខាង**

ខ្ញុំចូលចិត្តបង្រៀនអ្នកជិតខាងរបស់ខ្ញុំ នៅពេលយើងលេង ដោយសារខ្ញុំចង់បម្រើពួកគេ ។ នៅក្នុង ម៉ាថាយ ៥:១៦ ព្រះយេស៊ូវបង្រៀនយើងថា ចូរឲ្យយើងបញ្ចាំងពន្លឺយើងចេញទៅ ។ ពេលខ្ញុំធ្វើល្អដូច្នេះ ខ្ញុំមានអារម្មណ៍រីករាយ ។

**៣**

**ហូប៊ើត ៖ ការជួយអ្នកស្រេកឃ្លាន**

អំឡុងពេលចេញលេងនៅសាលារៀន ខ្ញុំឃើញមនុស្សដែលស្រេកឃ្លាន ហើយគ្មានអ្វីបរិភោគ ។ ខ្ញុំបានចែកអាហារសម្រន់របស់ខ្ញុំ ហើយបានជួយពួកគេឲ្យមានអារម្មណ៍ធូរស្បើយ ។ បន្ទាប់ពីចែកនំនោះរួច ខ្ញុំមានអារម្មណ៍រីករាយ ។






**៤**

**ហូប៊ើត ៖ ការលេងព្យាណូខ្យល់**

នៅព្រះវិហារខ្ញុំលេងព្យាណូខ្យល់សម្រាប់ឲ្យសមាជិកច្រៀង ។ ពេលខ្ញុំធ្វើល្អដូច្នេះ ខ្ញុំមានអារម្មណ៍រីករាយ ។



**៥**

**ចូរយើងបញ្ចាំងពន្លឺដល់ពិភពលោក**

នៅក្នុងព្រះគម្ពីរចែងថា ព្រះយេស៊ូវគឺជាពន្លឺ និងជាជីវិតនៃពិភពលោក ។ ដូច្នេះចូរយើងបញ្ចាំងពន្លឺដល់ពិភពលោក !

**សូមអរគុណដែលប្អូនៗបានផ្ញើរូបផ្កាយរបស់ប្អូនមកកាន់ *លីអាហូណា* !**

ឆ្នាំនេះ ប្អូនៗបានបំពេញមេឃរបស់យើងជាមួយនឹងរូបផ្កាយ និងរឿងរាប់ពាន់ស្ដីពីការបម្រើប្រកបដោយក្ដីស្រឡាញ់របស់ប្អូនៗ ។ ប្រាកដណាស់ ប្អូនៗពិតជាបានបញ្ចាំងពន្លឺរបស់ប្អូនៗមែន !